# អាងត្រពាំងថ្ម

**A1, A3, A4i & A4iii**



| | | |
|---|---|---|
| **ខេត្ត** | : | បន្ទាយមានជ័យ |
| **ស្រុក** | : | ភ្នំស្រុក |
| **ផ្ទៃដី ( ហិកតា)** | : | ១២.៦៥៩ |
| **រយៈកំពស់ ( ម៉ែត្រ)** | : | ១៤ ដល់ ២៧ |
| **កូអរដោនេចំណុចកណ្ដាល** | : | ១៣$^{0}$៥១´ជ ១០៣$^{0}$១៩´ក |

**ការពិពណ៌នាទីកន្លែង**

តំបន់ IBA នេះស្ថិតនៅក្នុងតំបន់ដែលអនុម័តដោយព្រះរាជក្រឹត្យដែលមានឈ្មោះថា "តំបន់គ្រប់គ្រង និង អភិរក្សដែនបំរុងសត្វក្រៀលអាងត្រពាំងថ្ម" ។ តំបន់នេះមានចំណុចកណ្ដាលត្រង់បឹងសិប្បនិម្មិតមួយស្ថិតនៅចំងាយ៧0គីឡូម៉ែត្រពីបឹងទន្លេសាបទិសពាយ័ព្យ ។ នៅក្នុងសម័យអង្គរពីសតវត្សទី១០ដល់១៣នៃគ្រឹះសករាជ ផ្លូវមេមួយត្រូវបានសាងសង់ឡើងកាត់តាមតំបន់នោះដែលនាំឱ្យមានធារទឹកកើនឡើងនៅប៉ែកខាងជើង ។ នៅឆ្នាំ ១៩៧៦ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ប៉ុលពត) ពលកម្មដោយចាប់បង្ខំកំលាំងមនុស្សត្រូវបានប្រែក្លាយផ្លូវមួយនោះទៅជាទំនប់ទឹកដែលមានប្រវែង១១គីឡូម៉ែត្រ និង បានសាងសង់ទំនប់មួយទៀត កាត់កែងទៅនឹងទំនប់នោះ ។ ទោះជាយ៉ាងណាក្ដី ការសាងសង់អាងនោះមិនបានរួចរាល់តាមផែនការដែលបានគ្រោងទុកឡើយ ។ ក្នុងអំឡុងពេលរដូវប្រាំង មានតែជ្រុងមួយរបស់អាងប៉ុណ្ណោះស្ថិតនៅប៉ែកអគ្នេយ៍នៅមានលិចទឹក រីឯនៅរដូវវស្សាតំបន់នេះត្រូវលិចទឹកជាង៨0ភាគរយ ។ តំបន់នេះបង្កើតបានជាវាលស្មៅលិចទឹកតាមរដូវកាល តំបន់ប៉ែកខាងជើងលិចទឹកក្នុងរយៈពេលខ្លីជាងក្នុងឆ្នាំនិមួយៗត្រូវបានគេប្រែក្លាយទៅជាដីដំណាំស្រូវរដូវវស្សា ទោះបីជាដីមួយចំនួនមិនត្រូវបានគេធ្វើស្រែជារៀងរាល់ឆ្នាំក៏ដោយ ចំណែកនៅចុងខាងជើងនៃតំបន់ IBA ប្រភេទទីជំរកមានលក្ខណៈជាព្រៃរបោះ ។

តំបន់នេះមានសារៈសំខាន់បំផុតក្នុងការទ្រទ្រង់កន្លែងស្នាក់អាស្រ័យ និង ប្រភពរកចំណីរបស់សត្វក្រៀលក្នុងប្រទេសកម្ពុជា ដែលជាចំនួនមួយមានសមាមាត្រពិសេសនៃចំនួនក្នុងពិភពលោក ។ ក្រៅពីប្រភេទសត្វក្រៀល តំបន់នេះបានទ្រទ្រង់ជាង ១%នៃចំនួនសត្វតាមជីវភូមិសាស្ត្រនៅអាស៊ីដូចជា ប្រវីក ទាកាប៉ាព្រៃ ចង្កៀលខ្យង និង អង្កត់ខ្មៅ ។ ជាងនេះទៀត នៅមានវត្តមាននៃបណ្ដាប្រភេទទទួលរងការគំរាមកំហែង និងជិតរងគ្រោះក្នុងពិភពលោក ដែលគេបានកត់ត្រានៅក្នុងតំបន់នោះផងដែររួមមានខ្សឹប (ជាប្រភេទអាចពងកូនក្នុងតំបន់នេះ) ត្រយ៉ងចំកំកស និង ត្រដក់ធំ ។ លើសពីនេះទៀត អកត្រីធំ (Pallas's Fish Eagle Haliaeetus leucoryphus ) ដែលជាប្រភេទគំរាមកំហែងពិភពលោក និង ជាប្រភេទខ្វាត់ព្រាត់ (Vagrant) ត្រូវបានកត់ត្រាពីតំបន់នេះផងដែរ ។

**ប្រភេទសត្វស្លាបសំខាន់ៗ**

| **ឈ្មោះខ្មែរ** | **ឈ្មោះអង់គ្លេស** | **ឈ្មោះវិទ្យាសាស្ត្រ** | **លក្ខណៈវិនិច្ឆ័យIBA** | |
|---|---|---|---|---|
| ក្រៀល | Sarus Crane | Grus antigone | A1 | A4i |
| ខ្សឹប | Bengal Florican | Houbaropsis bengalensis | A1 | |

| | | | | |
|---|---|---|---|---|
| ចាបពូកទ្រូងលឿង | Asian Golden Weaver | Ploceus hypoxanthus | A1 | |
| ចង្កៀលខ្យង | Asian Openbill | Anastomus oscitans | | A4i |
| ត្រដក់តូច | Lesser Adjutant | Leptoptilos javanicus | A1 | |
| ត្រដក់ធំ | Greater Adjutant | Leptoptilos dubius | A1 | |
| ត្រយ៉ងខ្លួន ស | Black-headed Ibis | Threskiornis melanocephalus | A1 | A4i |
| ត្រយ៉ងចំកំក ស | White-shouldered Ibis | Pseudibis davisoni | A1 | |
| ទាកាប៉ាព្រៃ | Comb Duck | Sarkidiornis melanotos | A4i | |
| ទុងប្រផេះ | Spot-billed Pelican | Pelecanus philippensis | A1 | A4i |
| ប្រវឹក | Lesser Whistling-Duck | Dendrocygna javanica | | A4i |
| រនាលពណ៌ | Painted Stork | Mycteria leucocephala | A1 | |
| រនាល ស | Milky Stork | Mycteria cinerea | A1 | |
| ស្មោញ | Darter | Anhinga melanogaster | A1 | |
| អកខ្មៅដីសើម | Greater Spotted Eagle | Aquila clanga | A1 | |
| អង្កត់ខ្មៅ | Black-necked Stork | Ephippiorhynchus asiaticus | A1 | A4i |
| ឥន្ទ្រីយ៍ | Imperial Eagle | Aquila heliaca | A1 | |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបបីប្រភេទរស់នៅក្នុងប្រភេទព្រៃតំបន់ភ្នំខ្ពស់ៗ (The Sino-Himalayan Subtropical Forests) ពីរប្រភេទរស់នៅក្នុងប្រភេទព្រៃស្រោង (The Indochinese Tropical Moist Forests) ប្រាំពីរប្រភេទរស់នៅក្នុងប្រភេទព្រៃរបោះ (The Indo-Malayan Tropical Dry Zone) និង មួយប្រភេទរស់នៅក្នុងតំបន់ទំនាបវាលស្មៅ (The Indo-Gangetic Plains) (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរថាតិទទួលរងការគំរាមកំហែងពិភពលោក**

ស្វាក្តាម ។

**ថនិ និង ពពួកក្រចកជំពាចទទួលរងការគំរាមកំហែងពិភពលោក**

រមាំង ។

**ប្រភេទអណ្តើក កន្ធាយ និង ក្រពើទទួលរងការគំរាមកំហែងពិភពលោក**

អណ្តើកបិទមុខស្នូកខ្មៅ អណ្តើកសកល និង អណ្តើកព្រិច ។

**ការគំរាមកំហែងលើជីវៈចំរុះ**

មុនពេលមានការបង្កើតតំបន់គ្រប់គ្រង និង អភិរក្សដែនបំរុងសត្វក្រៀលអាងត្រពាំងថ្មនៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០០ ប្រជាពលរដ្ឋមូលដ្ឋានធ្លាប់ទាក់ចាប់សត្វក្រៀលជាទៀងទាត់ដោយប្រើប្រាស់ថ្នាំពុល ។ នៅឆ្នាំ ១៩៩៩ ការធ្វើពាណិជ្ជកម្មសត្វព្រៃមានកំរិតខ្ពស់ ដោយមានតម្រូវការពីប្រទេសថៃ ។ ការទាក់ចាប់ និង ការប្រមាញ់សត្វក្រៀលក្នុងពេលបច្ចុប្បន្ន ត្រូវបានកាត់បន្ថយយ៉ាងច្រើនតាមរយៈការអនុវត្តន៍ច្បាប់ និង សកម្មភាពផ្សព្វផ្សាយចំណេះដឹង ទោះជានៅមានការបរបាញ់ជាទ្រង់ទ្រាយតូចៗនៃប្រភេទផ្សេងៗទៀតកើតឡើងក៏ដោយ ។ ការគំរាមកំហែងចំបងបំផុតកើតឡើងនៅក្នុងតំបន់នេះនាពេលបច្ចុប្បន្នគឺការប្រែក្លាយតំបន់វាលស្មៅ និង តំបន់ព្រៃឈើទៅជាដីកសិកម្ម ហើយការគំរាមកំហែងរយៈពេលយូរមានសក្តានុពលអាចជាការរៀបចំផ្គត់ផ្គង់កំរិតកំពស់ទឹកនៅក្នុងអាងសម្រាប់ការស្រោចស្រពដំណាំកសិកម្មនៅផ្នែកខាងក្រោម ។

**អនុសាសន៍**

សកម្មភាពអនុវត្តច្បាប់នៅអាងត្រពាំងថ្មនាពេលថ្មីៗនេះដែលបានផ្តោតលើការត្រួតពិនិត្យនៃការបរបាញ់សត្វព្រៃគួរតែត្រូវធ្វើបន្តទៀត ។

ផែនការគ្រប់គ្រងដែលមានការបែងចែកតំបន់បំរុងទុកការប្រើប្រាស់ដីជាលក្ខណៈផ្សេងៗ ជាពិសេសការកំណត់ព្រំប្រទល់តំបន់កសិកម្មគួរតែមានការឯកភាពពីអ្នកពាក់ព័ន្ធទាំងឡាយឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ហើយពង្រឹងការអនុវត្តន៍ច្បាប់ឱ្យបានតឹងរឹង ។

កម្មវិធីអភិវឌ្ឍន៍សហគមន៍គួរតែផ្តួចផ្តើមធ្វើឡើងនៅតាមភូមិនានាដែលស្ថិតនៅក្នុង ឬ នៅជាប់តំបន់បំរុងទុក ដោយផ្តោតលើជីវភាពរស់នៅប្រកបដោយនិរន្តរភាព ។

គំរោងការផ្នែកទេសចរណ៍គួររៀបចំបង្កើតឡើង តែគិតគូរពិចារណាអំពីផលប៉ះពាល់លើតំបន់បំរុងទុក និង ផលប្រយោជន៍នៃការអនុវត្តន៍គ្រប់គ្រងបានល្អសម្រាប់សហគមន៍មូលដ្ឋាន ។

ការរានដីព្រៃ និង ការទន្ទ្រានយកដីនៅក្នុង និង ជុំវិញតំបន់នេះគឺជាបញ្ហាស្មុគស្មាញនៅពេលបច្ចុប្បន្ន ដូច្នេះ កិច្ចព្រមព្រៀងលើសិទ្ធិកាន់កាប់ និង ប្រើប្រាស់ដីធ្លី គឺជាតម្រូវការចាំបាច់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការគ្រប់គ្រងតំបន់បំរុងទុកឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**ឯកសារយោង**


Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Goes, F. and Hong Chamnan (2001) *Ang Trapeang Thmor Sarus Crane Conservation Area: a major site for bird conservation in north-west Cambodia*. Phnom Penh: Wildlife Conservation Society.

Sam Veasna (1998) *Report on research and survey towards the protection of Sarus Crane and other bird species. Ang Tropeang Thmor site, Bantey Meanchey province, Cambodia*. Unpublished report.

Sam Veasna (1998) *Endangered birds in north-western Cambodia.* Paper presented at the Important Bird Areas Workshop, Phnom Penh, March 1998.

Sam Veasna, Hong Chamnan, Thach Savany and Briggs, E. (1998) *Trip to Banteay Meanchay province, April 18-20 1998: report on the status of Sarus Crane in northwest Cambodia.* Unpublished report.

Sam Veasna and Mundkur, T. (1998) *New site of international importance for Sarus Crane discovered in Cambodia*. Unpublished report.